

# កំណាព្យ

## គន្ធ នៃ អទ្ធា

Odeur du temps

បទព្រហ្មគីតិ

វិជាត[1]កាលមានគន្ធ[2]   កាយនៅទន់ដេកក្បែរម្ដាយ
អទ្ធា[3]មានក្លិនសាយ   សុខសាន្តត្រាណសូមសាធុ។
ពីមាតាបិតា   សាធុការពរព្រះពុទ្ធ
ទទួលយកមកទុក   ក្នុងបន្ទុក[4]ជាកតញ្ញូ។

កុមារភាពម៉ែថៃ   ពុកនៅក្បែរជាគ្រូចិត្ត
ជាគន្ធទេ្វមានឫទ្ធិ   កាលជិវិតមានផ្លូវល្អ។
ពុកម៉ែជាគំរូ   គុណលោកទូរ[5]ធម៌បវរ
ច្បាប់លោកជាភូធរ[6]   វិចិត្រករឆ្លាក់ចិត្តកូន។
ពេលលោកដល់ជរា   កិច្ចបុត្តា[7]ត្រូវនៅក្បែរ
ខំផ្ចិតផ្ចង់ពុកម៉ែ   សងលោកថែទាំកូនចៅ។
គន្ធលោកនៅជាព្រះ   ចិត្តប្រទះផ្ដល់កក់ក្ដៅ
ជាបុណ្យឱ្យកូនចៅ   ធម៌ប្រដៅអរគុណលោក។

---

1 វិជាត : គុ. ដែលកើតមក។
2 គន្ធ : ក្លិន។
3 អទ្ធា : កាល
4 បន្ទុក : ប្រើជាករណីយកិច្ច។
5 ទូរ : កិ. ជៀបគ្នា។
6 ភូធរ : ន. អ្នកទ្រទ្រង់នៅលើផែនដី ឬ ភ្នំ។
7 បុត្តា : កូនប្រុសនិងស្រី។